# ឯកសារទស្សនទានស្តីពីអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅកម្ពុជា
## ខែតុលា ឆ្នាំ២០១០

## I. សារចេតា

អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាឧបករណ៍ដ៏សមស្របរបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តយុទ្ធសាស្ត្រតាមវិស័យ និងកំណែទម្រង់ស្នូលនានា ។ លើសពីនេះ ក៏ជាយន្តការសម្រាប់លើកកម្ពស់ភាពជាម្ចាស់នៃកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដើម្បីធានាសង្គតិភាពនៃការគ្រប់គ្រងធនធាន និងពង្រឹងសមត្ថភាពព្រមទាំងងការប្រើប្រាស់ប្រព័ន្ធជាតិ ហើយសំខាន់ជាងនេះ ដើម្បីសម្រេចលទ្ធផលនៃការអភិវឌ្ឍន៍ ។ ក្នុងវេទិកាកិច្ចសហប្រតិ- បត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ដែលបានប្រារព្ធនាខែមិថុនា ឆ្នាំ២០១០ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានអនុមតិលើអភិក្រមគ្រប់គ្រងទូទាំងតាមកម្មវិធីនេះ និងបានព្រមព្រៀងគ្នាក្នុងការរៀបចំនិងអនុវត្តអភិក្រមនេះ ដើម្បីបង្កើនប្រសិទ្ធភាពឱ្យបានជាអតិបរមាក្នុងការប្រើប្រាស់ធនធានទាំងក្នុងប្រទេស និងក្រៅប្រទេសសម្រាប់កិច្ចអភិវឌ្ឍន៍ ។

តាមនិយមន័យសាមញ្ញ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាវិធីសាស្ត្រធ្វើការរួមគ្នាដោយមានកិច្ចសម្របសម្រួល ដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរ ។ ក្នុងពេលដែលមិនទាន់មានទម្រង់គំរូសម្រាប់ការរៀបចំ និងការអនុវត្តន៍ក៏ដោយ ក៏ឯកសារទស្សនទាននេះគឺជាផែនទីចង្អុលផ្លូវ ដែលបានកំណត់អំពីគោលដៅនិងសមាសធាតុសំខាន់ៗនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ ឯកសារទស្សនទាននេះបានចាប់ផ្តើម ដោយបញ្ជាក់អំពីនិយមន័យ និងគោលបំណងនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ បន្ទាប់មក ក៏បានកំណត់អំពីសមាសធាតុសំខាន់ៗដែលអាចអនុមតិដោយក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលកំពុងធ្វើការជាមួយគ្នានៅតាមក្រុមការងារបច្ចេកទេសចម្រុះ ។ ឯកសារទស្សនទាននេះក៏បានស្នើ «ជម្រើសសម្រាប់ការគាំទ្រ» ដែលគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក. អ. ក/ គ. ជ. នា) ក្នុងឋានៈជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលនិងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ អាចផ្តល់តាមសំណើរបស់ក្រសួងនិងស្ថាប័ន ឬក្រុមការងារបច្ចេកទេសចម្រុះ ។

ការគាំទ្រនេះនឹងត្រូវរៀបចំ ដោយធ្វើកោសល្យវិច័យ និងកំណត់បញ្ហាប្រឈមនានារបស់វិស័យ ឬកម្មវិធីជាក់លាក់ ព្រមទាំងកំណត់ជំហានបន្ទាប់ដែលត្រូវអនុវត្តសម្រាប់គាំទ្រការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ ការគាំទ្រតាមដំណើរការបែបនេះត្រូវបានកំណត់ថាជា «ក្លីនិច» ។

## II. និយមន័យនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី

និយមន័យនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីត្រូវបានកំណត់ដោយផ្អែកតាមគោលដៅជាក់ស្តែង ។ ជាទូទៅគោលដៅទាំងនោះគឺ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការ***ដឹកនាំ*** វិស័យ (វិស័យសុខាភិបាល) បញ្ហាអន្តរវិស័យ (យេនឌ័រ) ឬកម្មវិធីកំណែទម្រង់ (ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ) ដោយមាន***ការសម្របសម្រួល*** ដើម្បីសម្រេចបាន ***លទ្ធផល*** ប្រកបដោយ ***ប្រសិទ្ធភាព*** និង ***ចីរភាព*** ។

***អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាវិធីសាស្ត្រនៃការធ្វើការជាមួយគ្នា ក្នុងភាពជាដៃគូ ដោយមានការសម្របសម្រួល ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចលទ្ធផល ប្រកបដោយប្រសិទ្ធភាពនិងចីរភាព ។***

វាក្យស័ព្ទគន្លឹះមួយចំនួនតម្រូវឱ្យមានការបកស្រាយបញ្ជាក់បន្ថែម ដូចខាងក្រោម ÷

***ភាពដឹកនាំ:*** អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាកម្មវិធីដែលគ្រប់គ្រងនិងដឹកនាំដោយប្រទេសជាដៃគូ ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកំណត់គោលនយោបាយ កំណត់វិធីសាស្ត្រនៃការប្រើប្រាស់ធនធាន កំណត់ទម្រង់សម្រាប់អនុវត្តនិងគ្រប់គ្រងការសម្របសម្រួល ព្រមទាំងបង្កើតយន្តការតាមដានប្រកបដោយប្រសិទ្ធភាព ។

***ការសម្របសម្រួល:*** ដៃគូទាំងអស់ក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីត្រូវចូលរួមក្នុងកិច្ចពិគ្រោះយោបល់និងត្រួតពិនិត្យកម្រិតគោលនយោបាយរបស់វិស័យ ។ ធនធានទាំងអស់ត្រូវរំលេចក្នុងក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយ និងមានសង្គតិភាព ហើយត្រូវស្របជាមួយនឹងថវិការដ្ឋ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ ភាពជាដៃគូត្រូវបានបង្កើតឡើងដើម្បីចែករំលែកព័ត៌មាន និងការរៀនសូត្រពីបទពិសោធន៍ ព្រមទាំងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ។

***លទ្ធផល:*** ក្របខ័ណ្ឌច្បាស់លាស់ស្តីពីលទ្ធផលរំពឹងទុក ទាំងនៅកម្រិតធាតុចេញ (Output) ទាំងនៅកម្រិតលទ្ធផលសម្រាប់រយៈពេលវែង (Outcome) ត្រូវផ្សារភ្ជាប់ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយនិងក្របខ័ណ្ឌចំណាយ ។ លទ្ធផលទាំងនេះត្រូវរំលេចនៅកម្រិតវិស័យ ឬក្នុងកម្មវិធី ហើយប្រភពធនធានក្រៅប្រទេសទាំងអស់ត្រូវបានផ្តល់សម្រាប់គាំទ្រការអនុវត្តន៍ឱ្យសម្រេចបាននូវលទ្ធផលទាំងនេះ ។ ក្របខ័ណ្ឌលទ្ធផលនៅកម្រិតគម្រោងក៏ត្រូវផ្អែកលើគោលនយោបាយរបស់វិស័យផងដែរ ។

***ប្រសិទ្ធភាព:*** របៀបរបបការងារសម្រាប់អនុវត្តក៏ត្រូវកំណត់ឱ្យឯកភាពផងដែរ ដើម្បីកាត់បន្ថយឱ្យបាននូវចំណាយផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាល សម្រាប់សម្រេចធាតុចេញ ។ ការត្រួតពិនិត្យគម្រោងទាំងឡាយក្នុងក្របខ័ណ្ឌនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងការផ្តោតលើការប្រើប្រាស់ប្រព័ន្ធជាតិ គឺជាសក្ខីកម្មសម្រាប់ជម្រុញនិងលើកកម្ពស់ប្រសិទ្ធភាព ។

***ចីរភាព:*** ត្រូវយកចិត្តទុកដាក់លើទិដ្ឋភាពខាងសមត្ថភាពនិងធនធានសម្រាប់រយៈពេលវែង ។ ធនធានរបស់វិស័យត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍសមត្ថភាពនិងប្រព័ន្ធជាតិ ។ លើសពីនេះ ក៏ត្រូវធ្វើសមាហរណកម្មក្របខ័ណ្ឌចំណាយចរន្តនិងចំណាយមូលធន ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងវិនិយោគសាធារណៈសម្រាប់រយៈពេលវែង ។ ដោយឡែក ការវាយតម្លៃគម្រោងថ្មី (ដោយយកចិត្តទុកដាក់លើចំណាយចរន្តសម្រាប់រយៈពេលវែង) និងការកំណត់ចំណាយសំខាន់ៗ (ការកំណត់ប្រភពធនធាននិងការធ្វើអាទិភាវូបនីយកម្មចំណាយសម្រាប់ធានាប្រសិទ្ធភាព) ព្រមទាំងការរំលេចប្រភពធនធាននិងចំណាយទាំងអស់នៅក្នុងក្របខ័ណ្ឌថវិការបស់វិស័យ គឺជាវិធីសាស្ត្រសម្រាប់លើកកម្ពស់ចីរភាព ។

ទន្ទឹមនឹងនេះ យើងគួរកត់សម្គាល់ផងដែរថា ÷

១- មិនទាន់មានកិច្ចប្រតិបត្តិជាក់លាក់ណាមួយនៅឡើយ ។ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីត្រូវបានប្រើប្រាស់សម្រាប់អនុវត្តកម្មវិធីជាតិ ហើយធនធានទាំងអស់ ទាំងក្នុងប្រទេសនិងក្រៅប្រទេស ត្រូវបានគ្រប់គ្រងនៅក្នុងក្របខ័ណ្ឌពេញលេញមួយ ។

២- មិនទាន់មានគំរូដាច់ខាតណាមួយសម្រាប់អភិក្រមគ្រប់គ្រងតាមកម្មវិធីនៅឡើយ ទោះបីជាអភិក្រមនេះទាមទារឱ្យមានសមាសធាតុមួយចំនួនដែលត្រូវផ្អែកលើកំណែទម្រង់វិស័យសាធារណៈ (ឧទាហរណ៍ដូចជាប្រសិទ្ធភាព លទ្ធផលការងារ និងគណនេយ្យភាពជាដើម) ក៏ដោយ ។

## III. សមាសធាតុសំខាន់ៗនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី

ផ្អែកតាមនិយមន័យនិងគោលការណ៍នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី សមាសធាតុមូលដ្ឋាននៃអភិក្រមនេះត្រូវបានកំណត់ដូចខាងក្រោម ÷

ក- <u>ក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់</u>: ក្របខ័ណ្ឌនេះគឺជាមូលដ្ឋានសម្រាប់កំណត់វិស័យ និងកំណត់ការចូលរួមនិងធនធានរបស់ដៃគូទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស ក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ រាជរដ្ឋាភិបាលត្រូវធ្វើជាម្ចាស់លើគោលនយោបាយ ។ ការប៉ាន់ស្មានចំណាយត្រូវមានសង្គតិភាពជាមួយនឹងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។

ខ- <u>គោលដៅរួម</u>: គោលដៅទាំងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់នៅក្នុងក្របខ័ណ្ឌគោលនយោបាយ ដោយកំណត់គោលដៅនានាដែលបានព្រមព្រៀង និងយន្តការរួមគ្នាសម្រាប់តាមដាន ។

គ- <u>ក្របខ័ណ្ឌធនធានច្បាស់លាស់</u>: ផែនការសកម្មភាពប្រចាំឆ្នាំ (និង/ឬក្របខ័ណ្ឌរយៈពេលមធ្យមដែលភ្ជាប់នឹងថវិកា) ត្រូវបានរៀបចំដោយផ្អែកថវិកាតាមកម្មវិធីក្នុងក្របខ័ណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ផែនការសកម្មភាពប្រចាំឆ្នាំគឺជាមូលដ្ឋានសម្រាប់វិភាជន៍ធនធានកម្រិតយុទ្ធសាស្ត្រ និងជំរុញឱ្យមានសង្គតិភាព ការធ្វើអាទិភាវូបនីយកម្ម លើកកម្ពស់ប្រសិទ្ធភាពនិងចីរភាពក្នុងកម្មវិធីនីយកម្ម និងការចំណាយ (និងការតាមដានលទ្ធផលតាមរយៈតម្លាភាពនៃធាតុចូលដែលមាន និងការវិភាជន៍ធាតុចូលទាំងនេះ) ។

ឃ- <u>ទម្រង់នៃភាពជាដៃគូនិងកិច្ចពិគ្រោះយោបល់</u>: យន្តការសម្របសម្រួលត្រូវបានបង្កើតឡើង (ដូចជាក្រុមការងារបច្ចេកទេសចម្រុះ) សម្រាប់ពិភាក្សាកម្រិតគោលនយោបាយ ក៏ដូចជាកំណត់ឱ្យបានច្បាស់អំពីតួនាទីនិងការទទួលខុសត្រូវ និងសម្រាប់គាំទ្រដល់ការអនុវត្តន៍និងការត្រួតពិនិត្យ (សូមពិនិត្យ «សេចក្តីណែនាំស្តីពីតួនាទីនិងការប្រព្រឹត្តទៅនៃក្រុមការងារបច្ចេកទេសចម្រុះ») ។ គោលការណ៍ស្តីពីភាពជាដៃគូដែលបានចរចានិងឯកភាពក៏អាចជួយកំណត់តួនាទីនិងការទទួលខុសត្រូវ ហើយក៏ជួយជម្រុញគណនេយ្យភាពទ្វេទិសនៃភាពជាដៃគូផងដែរ ។

ង- <u>ការរៀបចំស្ថាប័ន និងការទទួលខុសត្រូវ</u>: ការគ្រប់គ្រង ការរៀបចំផែនការ ការពិគ្រោះយោបល់ ការអនុវត្តន៍ការងារ ការធ្វើរបាយការណ៍ ការតាមដាននិងត្រួតពិនិត្យ មិនទាមទារឱ្យរៀបចំរួមគ្នាទេ ពិសេសនៅក្នុងដំណាក់កាលដំបូង ប៉ុន្តែត្រូវមានភាពច្បាស់លាស់ និងត្រូវមានការឯកភាពគ្នា ។ សូចនាករស្តីពីលទ្ធផលការងារ និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតាមដានលទ្ធផល ។

ច- សមាសធាតុស្តីពីការអភិវឌ្ឍន៍សមត្ថភាពៈ ត្រូវវាយតម្លៃរួមនៅដំណាក់កាលដំបូងនៃការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីធានាឱ្យមានទស្សនទានឯកភាពគ្នាក្នុងការពង្រឹងសមត្ថភាពនិងប្រព័ន្ធជាតិសម្រាប់ឈានទៅសម្រេចលទ្ធផលនានាដែលមានចែងនៅក្នុងឯកសារក្របខ័ណ្ឌគោលនយោបាយ ។ ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ក្រៅប្រទេសក៏ត្រូវបានសម្របសម្រួល សម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាព និងការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីផងដែរ ។

ទន្ទឹមនឹងនេះ ក៏មានសមាសធាតុ និងកំណត់សម្គាល់បន្ថែមមួយចំនួនទៀតដែលត្រូវពិចារណា នៅពេលអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី :

- អង្គការសង្គមស៊ីវិលក៏អាចចូលរួមក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីបានដែរ ទោះបីជាធនធានរបស់ពួកគេត្រូវបានគ្រប់គ្រងក្រៅប្រព័ន្ធរាជរដ្ឋាភិបាលក៏ដោយ ។ ទន្ទឹមនេះ អង្គការសង្គមស៊ីវិលអាចផ្តល់ធាតុចូលសម្រាប់រៀបចំគោលនយោបាយឬអាចផ្តល់ការគាំទ្រសម្រាប់ការអនុវត្តន៍និងការតាមដាន ។ ទាំងនេះបានឆ្លុះបញ្ចាំងអំពីភាពទន់ភ្លន់នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីដែលអាចទទួលយកគ្រប់ទម្រង់នៃកិច្ចសហប្រតិបត្តិការទាំងអស់ ។
- អភិក្រមស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការអាចកំណត់ច្បាស់លាស់នៅក្នុងគោលការណ៍ស្តីពីភាពជាដៃគូ ឬនៅក្នុងសមាសភាគនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការរបស់វិស័យ ។ ទន្ទឹមនឹងនេះដែរ ចំណាត់ការនានាស្តីពីប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនឹងអាចរំលេចក្នុងឯកសារគោលនយោបាយ ឬនៅក្នុងការរៀបចំស្ថាប័ន ដូចជាលក្ខខ័ណ្ឌយោងរបស់ក្រុមការងារបច្ចេកទេសចម្រុះជាដើម ។
- កំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល (ដូចជាក្នុងរដ្ឋបាលសាធារណៈ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) នឹងត្រូវបញ្ចូលទៅក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ដើម្បីធានាឱ្យមានសង្គតិភាពខាងគោលនយោបាយ និងដើម្បីផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការអភិវឌ្ឍន៍សមត្ថភាពក្នុងពេលអនុវត្តអភិក្រមនេះ ។
- ការរៀបចំបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីត្រូវចាត់ទុកថាជាកិច្ចដំណើរការ ហើយមិនត្រូវចាត់ទុកថាជាសកម្មភាពអនុវត្តតែម្តងហើយចប់សព្វគ្រប់នោះឡើយ ។ សមាសធាតុនានានៃអភិក្រមនេះត្រូវបានបង្កើត និងពង្រឹងជាបន្តបន្ទាប់ ។
- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីមិនមែនជាទម្រង់នៃការផ្តល់ហិរញ្ញប្បទានឡើយ ។ ធាតុពិត នេះគឺជាដំណើរការសម្រាប់ធានាភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើអភិក្រមគោលនយោបាយ ដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ ។ លើសពីនេះ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីមិនមែនមានន័យត្រឹមតែការផ្តល់ហិរញ្ញប្បទានជាកញ្ចប់ ឬហិរញ្ញប្បទានសម្រាប់គាំទ្រថវិកា ហើយមិនរាប់បញ្ចូលបណ្តាគម្រោងនានានោះឡើយ ។ ប៉ុន្តែ ផ្ទុយមកវិញ ដៃគូអភិវឌ្ឍន៍ទាំងអស់ និងគ្រប់ទម្រង់ហិរញ្ញប្បទាន រួមមានថវិកាក្នុងប្រទេស ការផ្តល់ហិរញ្ញប្បទានតាមរយៈគម្រោង ការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ហិរញ្ញប្បទានសម្រាប់វិនិយោគ ហិរញ្ញប្បទានជាកញ្ចប់ និងហិរញ្ញប្បទានគាំទ្រថវិកា ត្រូវធានាថាការគាំទ្រទាំងអស់របស់ខ្លួនត្រូវរំលេចក្នុងក្របខ័ណ្ឌគោលនយោបាយ និងផែនការសកម្មភាពនិងថវិកា ។

## *អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាដំណើរការកម្រិតគោលនយោបាយ ដែលអាចទទួលយកបណ្តាដៃគូ និងទម្រង់ការហិរញ្ញប្បទានទាំងអស់*




## IV. អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីក្នុងបរិការណ៍កម្ពុជា

អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាយន្តការមួយដែលជួយដល់ការរៀបចំកម្មវិធីតាមវិស័យ និងកំណែទម្រង់នានាឱ្យមានភាពប្រសើរឡើង តាមរយៈការចូលរួមរបស់ប្រតិបត្តិករ និងទម្រង់ដំណើរការទាំងអស់ ។ អភិក្រមនេះក៏អាចចាត់ទុកថាជារបៀបធ្វើការងារថ្មី និងខុសប្លែកពីមុន ។ ធាតុពិត នេះគឺជាវិធីសាស្ត្រសាមញ្ញមួយសម្រាប់ពង្រឹង និងផ្សាភ្ជាប់ ព្រមទាំងគ្រប់គ្រងសកម្មភាពនានាក្នុងក្របខ័ណ្ឌភាពជាដៃគូដែលបានបង្កើតកន្លងមក ។ គោលដៅចម្បងនៃអភិក្រម ពោលគឺការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ការបង្កើនលទ្ធផលការងារ និងការលើកកម្ពស់ប្រសិទ្ធភាព មានសង្គតិភាពជាមួយនឹងគោលដៅនិងអភិក្រមនៃកំណែទម្រង់ស្នូលនានារបស់រាជរដ្ឋាភិបាល ក៏ដូចជាគោលការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដែលបានអនុម័ត ទាំងនៅកម្រិតសកល ទាំងនៅកម្រិតជាតិ ។ ដោយផ្តោតលើវិស័យ ឬកំណែទម្រង់ គ្រប់ដៃគូនិងធនធានរបស់ខ្លួន ទាំងក្នុងនិងក្រៅប្រទេសត្រូវធ្វើការជាមួយគ្នា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល សម្រាប់រៀបចំ និងអនុវត្ត ព្រមទាំងត្រួតពិនិត្យសកម្មភាពនៅកម្រិតវិស័យ ឬកម្មវិធី ។

របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០១០បានបញ្ជាក់យ៉ាងច្បាស់អំពីគុណប្រយោជន៍នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ បន្ថែមលើការជំរុញសុខដុមនីយកម្មក្នុងនីតិវិធី និងការបង្កើនប្រសិទ្ធភាព អភិក្រមនេះបានផ្តល់ភាពទន់ភ្លន់សម្រាប់ដោះស្រាយបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការដែលកើតមានឡើងស្ទើរនៅគ្រប់វិស័យនិងកម្មវិធីកំណែទម្រង់នានាក្នុងបណ្តាឆ្នាំកន្លងមក ÷

- ភាពដឹកនាំត្រូវបានពង្រឹង តាមរយៈការធានាឱ្យមានសង្គតិភាពរវាងក្របខ័ណ្ឌគោលនយោយ និងក្របខ័ណ្ឌហិរញ្ញប្បទាន ។
- អាចគ្រប់គ្រងហិរញ្ញប្បទានដែលមានលក្ខណៈបែកខ្ញែក និងហិរញ្ញប្បទានដែលបានពីប្រភពផ្សេងៗគ្នា ព្រមទាំងទម្រង់ការខុសៗគ្នា តាមរយៈការរៀបចំផែនការ ការវិភាជន៍ធនធាន និងដំណើរការត្រួតពិនិត្យតែមួយ ។
- ការអភិវឌ្ឍន៍សមត្ថភាព និងការពង្រឹងប្រព័ន្ធជាតិអាចសម្រេចបានតាមរយៈការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេសឱ្យកាន់តែប្រសើរឡើង ដោយផ្តោតសំខាន់លើគោលដៅនៅកម្រិតវិស័យ ជាជាងគោលដៅនៅកម្រិតគម្រោង ។
- ជវភាពនៃភាពជាដៃគូត្រូវបានកែលំអ ដែលនាំទៅដល់ការបង្កើនប្រសិទ្ធភាពកាន់តែខ្ពស់ និងលទ្ធផលកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់យន្តការសម្របសម្រួលនិងពិភាក្សាឱ្យមានប្រសិទ្ធភាពបន្ថែមទៀត ។
- សុខដុមនីយកម្មនៃហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានជំរុញតាមរយៈការបង្កើតប្រព័ន្ធនិងនីតិវិធីរបស់រាជរដ្ឋាភិបាល ដោយផ្សាភ្ជាប់ដំណាក់កាលនិមួយៗក្នុងវដ្តនៃផែនការនីយកម្មដែលរួមបញ្ចូលការរៀបចំផែនការ ការរៀបចំកម្មវិធី និងការត្រួតពិនិត្យលទ្ធផល ។

បន្ថែមលើការយកចិត្តទុកដាក់ក្នុងការពង្រឹងភាពជាម្ចាស់និងការអភិវឌ្ឍន៍សមត្ថភាព និងដោយធ្វើការក្នុងក្របខ័ណ្ឌគោលនយោបាយនិងផែនការរួមតែមួយ យើងអាចគ្រប់គ្រងធនធានដែលមានប្រភពផ្សេងៗពីគ្នា និងទម្រង់ការខុសៗគ្នាប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចឱ្យបាននូវលទ្ធផលដែលបានរំពឹងទុក ។ ក្នុងស្មារតីនេះ អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅកម្ពុជាមិនមែនមានន័យត្រឹមកិច្ចប្រតិបត្តិក្នុងការផ្តល់ហិរញ្ញប្បទានតែប៉ុណ្ណោះទេ ប៉ុន្តែ គឺជាមូលដ្ឋានសម្រាប់ពង្រឹងភាពដឹកនាំនិងចាត់ចែងការងារនៅកម្រិតវិស័យសម្រាប់គ្រប់គ្រងធនធានទាំងអស់របស់វិស័យ សំដៅសម្រេចឱ្យបានលទ្ធផល ។

ផ្អែកតាមបទពិសោធន៍ចាប់ពីឆ្នាំ២០០៦មក នៅពេលដែល«*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*» បានកំណត់ជាលើកដំបូង នូវអភិក្រមសម្រាប់ការអភិវឌ្ឍន៍និងកំណែទម្រង់តាមវិស័យ បណ្តាចំណុចដូចខាងក្រោមនេះមានសារៈសំខាន់សម្រាប់រៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅកម្ពុជា ÷

- ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានភាពដឹកនាំប្រកបដោយជំនាញខ្ពស់ និងរឹងមាំរបស់រាជរដ្ឋាភិបាលក្នុងការបំពេញការងារជាមួយនឹងដៃគូជាច្រើន សម្រាប់ចរចាអំពីគោលដៅ កៀរគរធនធាន និងអនុវត្តកម្មវិធី ។ គំនិតផ្តួចផ្តើមស្តីពីការធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ជវភាពនៃភាពជាដៃគូ ។

- ទោះជាទម្រង់ការអនុវត្តបែបណាក៏ដោយ ក៏កិច្ចប្រឹងប្រែងសំខាន់គឺត្រូវរំលេចគ្រប់ធនធានទាំងអស់នៅក្នុងក្របខ័ណ្ឌថវិការួម (ដូចជាផែនការយុទ្ធសាស្ត្រថវិកានៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ) ដែលជំរុញឱ្យមានសង្គតិភាពក្នុងការធ្វើផែនការតាមវិស័យ ការវិភាជន៍ធនធាន និងការត្រួតពិនិត្យលទ្ធផលរួមគ្នាប្រកបដោយភាពស្វាហាប់ ។
- ការរៀបចំការអនុវត្តន៍និងការគ្រប់គ្រងត្រូវពិនិត្យឱ្យលើសពីកម្រិតគម្រោង ដើម្បីឈានទៅធ្វើសុខដុមនីយកម្មជាជំហានៗក្នុងការប្រើប្រាស់ប្រព័ន្ធជាតិ ។ ទីប្រឹក្សានិងអ្នកឯកទេសត្រូវផ្តល់ការគាំទ្រសម្រាប់ពង្រឹងប្រព័ន្ធនិងសមត្ថភាពរបស់វិស័យ (មិនត្រូវផ្តោតត្រឹមតែលទ្ធផលរបស់គម្រោងនោះឡើយ) ។
- កំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាល បានផ្តល់វិធីសាស្ត្រថ្មីៗសម្រាប់រៀបចំនិងគ្រប់គ្រងសកម្មភាពរបស់រាជរដ្ឋាភិបាលនិងការអភិវឌ្ឍន៍សមត្ថភាព ។ កំណែទម្រង់ទាំងនេះត្រូវរំលេចនៅក្នុងការងាររបស់វិស័យ និងកម្មវិធីគាំទ្ររបស់ដៃគូក្នុងវិស័យនោះ ។
- ការបញ្ជាបបញ្ហាអន្តរវិស័យ និងការចូលរួមនិងតួនាទីរបស់សង្គមស៊ីវិលត្រូវកំណត់ឱ្យបានច្បាស់លាស់សម្រាប់អនុវត្ត ក្នុងបរិការណ៍នៃអភិក្រមដែលមានភាគីពាក់ព័ន្ធច្រើន ។

## V. ដំណើរការរៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និង «ភ្ជិនិច»

ក្នុងដំណាក់កាលដំបូងនៃការរៀបចំ ការយល់ដឹងរួមគ្នាអំពីសារជាតិនិងគោលដៅនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីរវាងដៃគូទាំងអស់នៅក្នុងវិស័យ គឺជាបញ្ហាសំខាន់ ។ វិស័យ ឬក្រុមការងារបច្ចេកទេសនិមួយៗត្រូវមានសមត្ថភាពក្នុងការបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ÷

- ចំណុចចាប់ផ្តើម ដែលពាក់ព័ន្ធនឹងការយល់ដឹងអំពីការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងអំពីគុណប្រយោជន៍ ព្រមទាំងការងារពាក់ព័ន្ធនានាសម្រាប់ជម្រុញការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

- សនិទានកម្មក្នុងការបង្កើតអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី រួមទាំងបញ្ហាក្នុងភាពជាដៃគូ និងការសម្របសម្រួល ដែលជាមូលដ្ឋានក្នុងការអនុមតិអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

- លទ្ធផលដែលត្រូវសម្រេចឱ្យបាន (លទ្ធផលចុងក្រោយ) ក៏ដូចជាសមាសភាពសំខាន់ៗដែលត្រូវពង្រឹង (ឧបករណ៍ឬមធ្យោបាយ) ។

- អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីផ្តល់កាលានុវត្តភាពសម្រាប់ពង្រឹងយុទ្ធសាស្ត្រនៃភាពជាដៃគូ (ទាំងក្នុងនិងក្រៅរាជរដ្ឋាភិបាល) ។

- វឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលដែលជះឥទ្ធិពលដល់ការងាររបស់វិស័យ និងកាលានុវត្តភាពដែលកម្មវិធីកំណែទម្រង់ទាំងនេះ អាចផ្តល់ និងផ្សាភ្ជាប់នឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

ចំណុចសំខាន់គឺត្រូវយល់ឱ្យបានឯកភាពគ្នាថា អភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺជាកិច្ចដំណើរការដែលឈរលើមូលដ្ឋានគ្រឹះដែលមានស្រាប់ ។ មូលដ្ឋានគ្រឹះទាំងនោះរួមមានផែនការរបស់វិស័យដែលមានស្រាប់ កម្មវិធីកំណែទម្រង់ដែលផ្សាភ្ជាប់នឹងវិស័យ (ពិសេសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) ការរៀបចំភាពជាដៃគូ

ក្របខ័ណ្ឌលទ្ធផល គំនិតផ្ដួចផ្ដើមស្ដីពីការអភិវឌ្ឍន៍សមត្ថភាព និងការផ្ដល់ទីប្រឹក្សា ។ ប៉ុន្ដែ តម្រូវការជាអប្បរមាសម្រាប់ឈានទៅអនុវត្ដអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីគឺអត្ថិភាពនៃកម្មវិធីរបស់វិស័យ (ដូចជាផែនការយុទ្ធសាស្ដ្រ ឬផែនការរយៈពេលមធ្យម) ដែលជាមូលដ្ឋានក្នុងការពង្រឹងភាពដឹកនាំនិងការសម្របសម្រួល ។ រីឯសមាសធាតុនិមួយៗនៃអភិក្រមនេះអាចពង្រឹងជាបន្ដបន្ទាប់តាមលក្ខណៈជាក់ស្ដែងនៃសមាសធាតុ ដោយត្រូវធានាសង្គតិភាពក្នុងទំនាក់ទំនងរវាងបណ្ដាសមាសភាពទាំងអស់ ។ ជាទូទៅ កិច្ចដំណើរការរៀបចំអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីអាចចាប់ផ្ដើមពីសេចក្ដីថ្លែងការណ៍កម្រិតគោលនយោបាយនិងគោលដៅ ការកំណត់ពីតម្រូវការខាងសមត្ថភាព និងការរៀបចំពង្រឹងភាពជាដៃគូនិងការសម្របសម្រួល ។ បន្ទាប់មក ការរៀបចំក្របខ័ណ្ឌផែនការនិងថវិកាគ្រប់ជ្រុងជ្រោយ និងការរៀបចំខាងស្ថាប័ន ព្រមទាំងក្របខ័ណ្ឌត្រួតពិនិត្យអាចអនុវត្ដក្នុងជំហានបន្ទាប់ ។

ដើម្បីជួយសម្រួលដល់ដំណើរការរៀបចំនិងការអនុវត្ដន៍ ព្រមទាំងផ្សាភ្ជាប់រវាងបណ្ដាសមាសភាគនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កំពុងរៀបចំការគាំទ្រសម្រាប់ក្រសួងនិងស្ថាប័ន ក៏ដូចជាក្រុមការងារបច្ចេកទេសចម្រុះ ក្នុងការជំរុញឱ្យបង្កើត និងអនុវត្ដអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ ការវាយតម្លៃរួមអំពីតម្រូវការនឹងត្រូវពិភាក្សារវាងក្រសួងនិងស្ថាប័នសាម៉ី (ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីមានពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) និងអ្នកសម្របស្រម្រួលខាងដៃគូអភិវឌ្ឍន៍ ព្រមទាំងជាមួយនឹងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយត្រូវឯកភាពពីក្រុមការងារបច្ចេកទេសចម្រុះ ។ ដំណើរការតាមរបៀបនេះដែលនឹងនាំទៅដល់ការគាំទ្រតាមរយៈ «ក្លីនិច» សម្រាប់ឆ្លើយតបនឹងតម្រូវការជាក់ស្ដែងរបស់វិស័យនិមួយៗ ។ សមាសធាតុសំខាន់ៗនៃ «ក្លីនិច» រួមមាន ÷

១- <u>អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី – បរិការណ៍នៃការប្រើប្រាស់</u> :

គោលដៅចម្បងនៃសមាសភាគនេះគឺដើម្បីធានាឱ្យគ្រប់សមាជិកទាំងអស់នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ឬក្រុមការងារបច្ចេកទេសចម្រុះមានការយល់ដឹងឯកភាពគ្នាអំពីអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីនៅក្នុងវិស័យ និងកម្មវិធីកំណែទម្រង់របស់ខ្លួន អំពីសក្ដានុពលក្នុងការអនុវត្ដន៍អភិក្រមនេះនិងបញ្ហាប្រឈម ព្រមទាំងការផ្សារភ្ជាប់អភិក្រមនេះទៅនឹងកំណែទម្រង់របស់រាជរដ្ឋាភិបាល ។

- និយមន័យនិងការវិវត្ដន៍នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។
- គោលដៅនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងគុណប្រយោជន៍ ។
- បរិបទនិងស្ថានភាពរបស់វិស័យ និងបញ្ហាប្រឈមនានាទាក់ទងនឹងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។
- បញ្ហាប្រឈមស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្ដិការនិងដំណោះស្រាយរហូតមកដល់បច្ចុប្បន្ន ។
- តួនាទីនៃកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល និងទំនាក់ទំនងជាមួយអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

២- <u>ប្រសិទ្ធភាព និងលទ្ធផល</u> :

សមាសធាតុនេះនឹងពិនិត្យអំពីលទ្ធភាពក្នុងការប្រើប្រាស់ប្រកបដោយភាពទន់ភ្លន់ នូវអភិក្រមផ្ដោតលើលទ្ធផល សម្រាប់ការរៀបចំផែនការ ការកៀរគរធនធាន និងការគ្រប់គ្រងដោយផ្ដោតលើលទ្ធផល ព្រមទាំងបញ្ហាអន្ដរវិស័យផងដែរ ។

- និន្នាការនៃកំណែទម្រង់វិស័យសាធារណៈនិងទំនាក់ទំនងជាមួយនឹងគោលដៅអភិវឌ្ឍន៍សហសវត្សន៍ ។
- ការប្រើប្រាស់អភិក្រមដោយផ្តោតលើលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។
- ការយល់ឃើញនិងទស្សនៈវិស័យផ្ទុយគ្នាក្នុងហិរញ្ញប្បទានសហប្រតិបត្តិការ (ការរៀបចំផែនការ និងការស្រាវជ្រាវ) ។
- សារៈសំខាន់នៃក្របខ័ណ្ឌគោលនយោបាយ និងថវិកា ។
- បញ្ហាអន្តរវិស័យ និងការគ្រប់គ្រងបញ្ហាអន្តរវិស័យទាំងនេះក្នុងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

៣- <u>ភាពជាដៃគូ និងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី</u> :

តួនាទីនៃភាពជាដៃគូក្នុងរាជរដ្ឋាភិបាល និងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិល មានសារៈសំខាន់បំផុតសម្រាប់អនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីប្រកបដោយប្រសិទ្ធភាព និងផ្តោតលើលទ្ធផល ។ ផ្នែកនេះនឹងបំភ្លឺបញ្ហានៃភាពជាដៃគូ និងការគ្រប់គ្រងព័ត៌មានស្តីពីកម្មវិធីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធានាឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

- កំណត់វិសាលភាពរបស់វិស័យនិងដៃគូសំខាន់ៗ ។
- ជម្រើសនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។
- គុណប្រយោជន៍នៃទម្រង់ការហិរញ្ញប្បទាននិមួយៗ ។
- ការប្រើប្រាស់ប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការក្នុងផែនការនីយកម្ម កម្មវិធីនីយកម្ម និងការសម្របសម្រួល ។
- ការតម្រឹម និងសុខដុមនីយកម្មតាមរយៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។
- ការធ្វើឱ្យភាពជាដៃគូកាន់តែមានប្រសិទ្ធភាព ។

៤- <u>ការអភិវឌ្ឍន៍សមត្ថភាព និងអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី</u> :

សារៈសំខាន់នៃការអភិវឌ្ឍន៍សមត្ថភាពសម្រាប់បុគ្គលិកម្នាក់ៗ សម្រាប់ប្រព័ន្ធនិងស្ថាប័ន គឺជាផ្នែកមួយដ៏សំខាន់នៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ គោលបំណងនៃផ្នែកគឺពិនិត្យឡើងវិញអំពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍន៍សមត្ថភាព និងលើកឡើងអំពីជម្រើសសម្រាប់អនុវត្តរួមគ្នា ។ ជម្រើសទាំងនេះត្រូវមានសង្គតិភាពជាមួយនឹងកម្មវិធីកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ។

- សារៈសំខាន់នៃកំណែទម្រង់ស្នូល និងប្រព័ន្ធជាតិ ។
- តួនាទីរបស់ដៃគូអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ។
- ការវាយតម្លៃសមត្ថភាពរួមគ្នា ។
- ការអនុវត្តន៍ ការតាមដាន និងគណនេយ្យភាពតាមរយៈក្របខ័ណ្ឌគោលនយោបាយនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។

ទម្រង់នៃ «ក្លីនិច» នឹងត្រូវកំណត់ដោយផ្អែកលើលទ្ធផលនៃការចរចារវាងប្រធានក្រុមការងារបច្ចេកទេសចម្រុះ អ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងសមាជិកដទៃទៀត ។ «ក្លីនិច» អាចអនុវត្តសម្រាប់ក្រុមតូចៗ (ដើម្បីរៀបចំគំនិតសំខាន់ៗ) ឬសម្រាប់ក្រុមទាំងមូល (សម្រាប់បង្កើនការយល់ដឹង និងការឯកភាពគ្នា) ឬរៀបចំ

សម្រាប់ក្រុមទាំងពីរប្រភេទនេះតាមលំដាប់លំដោយច្បាស់លាស់ ។ កិច្ចពិភាក្សាអំពី«ក្ដីនិច»និមួយៗត្រូវបញ្ចូលបញ្ហាស្ដីពីជំហានបន្ទាប់សម្រាប់អនុវត្ត និងវិធានការសម្រាប់តាមដានផងដែរ ។

## VI. សេចក្ដីសន្និដ្ឋាន

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានត្រៀមខ្លួនជាស្រេចសម្រាប់ផ្ដល់ប្រឹក្សាបច្ចេកទេស និងការគាំទ្រតាមតម្រូវការរបស់ក្រសួងនិងស្ថាប័ន ឬក្រុមការងារបច្ចេកទេសចម្រុះរបស់រាជរដ្ឋាភិបាលដែលមានបំណងរៀបចំនិងអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ។ លើសពីនេះ ក៏អាចប្រើប្រាស់ក្រុមការងារបច្ចេកទេសស្ដីពីភាពជាដៃគូនិងសុខដុមនីយកម្ម និងបណ្ដាញក្រុមការងារ សម្រាប់ជាវេទិការៀបចំទស្សនទាននៃ«ក្ដីនិច» សម្រាប់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី និងសម្រាប់រៀនសូត្រនិងចែករំលែកគំនិតយោបល់ជាមួយគ្នា ដែលទាំងនេះពិតជាអត្ថប្រយោជន៍សម្រាប់សមាជិកទាំងអស់ក្នុងកម្មវិធី និងកម្មវិធីកំណែទម្រង់ ។

បទពិសោធន៍ក្នុងការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី គឺជាមូលដ្ឋានសម្រាប់រាជរដ្ឋាភិបាលកំណត់គោលជំហរច្បាស់លាស់របស់ខ្លួន ដើម្បីបង្ហាញក្នុងវេទិកាកម្រិតខ្ពស់លើកទី៤ស្ដីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដែលនឹងប្រព្រឹត្តិទៅនៅសាធារណរដ្ឋកូរ៉េ នាខែវិច្ឆិកា ឆ្នាំ២០១១ ។ លើសពីនេះ ក៏ជាធាតុចូលយ៉ាងសំខាន់សម្រាប់រាជរដ្ឋាភិបាលរៀបចំក្របខ័ណ្ឌគោលនយោបាយស្ដីពីការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិ-បត្តិការ នាដើមឆ្នាំ២០១២ ផងដែរ ។

-------------

# ដំណាក់កាលសំខាន់ៗ និងសមាសធាតុនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី

**១- ការឯកភាពលើគោលដៅនៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី-** ការយល់ដឹងរួមគ្នាអំពីអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី បណ្តាគោលដៅ និងសមាសធាតុត្រូវកំណត់ដោយដៃគូទាំងអស់ ។

**២- ក្របខ័ណ្ឌគោលនយោបាយពេញលេញ-** នេះគឺជាការកំណត់អំពីវិស័យ ឬកម្មវិធី និងលទ្ធផលដែលត្រូវសម្រេច ។ ភាពដឹកនាំរបស់រាជរដ្ឋាភិបាលនិងការសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវបានពង្រឹង ស្របតាមក្របខ័ណ្ឌគោលនយោបាយដែលជាលក្ខខ័ណ្ឌអប្បរមានៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី

**៣- គោលដៅរួម-** លទ្ធផលដែលបានរំពឹងទុក និងដំណើរការសម្រាប់ការតាមដានត្រូវរំលេចក្នុងក្របខ័ណ្ឌគោលនយោបាយ

**៤- ក្របខ័ណ្ឌធនធានពេញលេញ-** ផែនការសកម្មភាពប្រចាំឆ្នាំដែលផ្សារភ្ជាប់ជាមួយនឹងថវិកា និងដែលផ្អែកតាមកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានគាំទ្រដល់ការវិភាជន៍ធនធានជាយុទ្ធសាស្រ្ត និងធានាចីរភាព ។

**៥- ភាពជាដៃគូនិងរចនាសម្ព័ន្ធសម្រាប់ការពិភាក្សា-** បង្កើតយន្តការសម្របសម្រួល (ដូចជាក្រុមការងារបច្ចេកទេសចម្រុះ) ដើម្បីពិភាក្សានិងពិនិត្យឡើងវិញនូវបណ្តាបញ្ហាដែលពាក់ព័ន្ធនឹងគោលនយោបាយ និងការអនុវត្តន៍ ។



**៦- ការឯកភាពក្នុងការរៀបចំស្ថាប័ន និងការទទួលខុសត្រូវ-** ប្រព័ន្ធសម្រាប់ការគ្រប់គ្រង ការរៀបចំផែនការ ការពិភាក្សា ការអនុវត្តន៍ ការធ្វើរបាយការណ៍ ការតាមដាន និងការពិនិត្យឡើងវិញ ត្រូវបានពង្រឹងដើម្បីជាជំហានៗឈានទៅប្រើប្រាស់ប្រព័ន្ធជាតិ ។

**៧- សមាសធាតុស្តីពីការអភិវឌ្ឍន៍សមត្ថភាព-** ការវាយតម្លៃរួមគ្នាបានបង្កើតអភិក្រមឯកភាពសម្រាប់ពង្រឹងសមត្ថភាពនិងប្រព័ន្ធជាតិ ដើម្បីសម្រេចលទ្ធផលដូចមានចែងក្នុងក្របខ័ណ្ឌគោលនយោបាយ ។

**៨- ការសិក្សានិងការសម្របខ្លួន-** ដំណើរការពិនិត្យតាមដានរួមគ្នាបានផ្តល់នូវយល់ដឹងរួមគ្នា និងការសម្របខ្លួនតាមគោលនយោបាយ និងកិច្ចប្រតិបត្តិនានានៃអភិក្រមគ្រប់គ្រងទូទាំងកម្មវិធីដោយផ្តោតលើលទ្ធផល ។